FCC Visit DTV.gov

# ការប្តូរទូរទស្សន៍ទៅជាឌីជីថល

## អ្វីដែលអ្នកត្រូវដឹងអំពីទូរទស្សន៍ឌីជីថល




### តើការប្តូរទូរទស្សន៍ឌីជីថល (DTV) គឺជាអ្វី ?

បច្ចុប្បន្ននេះ ស្ថានីយ៍ផ្សាយតាមរលកធាតុអាកាសជាច្រើន កំពុងផ្សព្វផ្សាយទាំងបែបសម្រាប់ទូរទស្សន៍អាណាឡូក និងទាំងឌីជីថល ។ បន្ទាប់ពីថ្ងៃទី 17 ខែ កុម្ភៈ ឆ្នាំ 2009 ទៅ ស្ថានីយ៍ទូរទស្សន៍ នឹងផ្សាយតែប្រភេទឌីជីថលប៉ុណ្ណោះ ។ ការប្តូរ DTV នឹងប៉ះពាល់ទៅលើអ្នកទាំងឡាយណាដែលមើលទូរទស្សន៍ឥតគិតថ្លៃដែលផ្សាយតាមរលកធាតុអាកាស (តាមរយៈអង់តែនលើដំបូល ឬ "ត្រចៀកទន្សាយ") ។ ប្រសិនបើអ្នកមើលកម្មវិធីផ្សេងៗដែលផ្សាយតាមរលកធាតុអាកាសដោយប្រើទូរទស្សន៍អាណាឡូក អ្នកត្រូវតែចាត់វិធានការណ៍ ឱ្យបានមុនថ្ងៃទី 17 ខែ កុម្ភៈ ឆ្នាំ 2009 ។

### ហេតុអ្វីបានជាស្ថានីយ៍ផ្សាយប្តូរទៅកាន់ឌីជីថល ?

ច្បាប់សហព័ន្ធតម្រូវឱ្យប្តូរ ដែលនឹងធ្វើឱ្យប្រេកង់មានភាពទូលាយសម្រាប់ទំនាក់ទំនងរបស់ប៉ូលីស អគ្គីភ័យ និងសង្គ្រោះបន្ទាន់ អនុញ្ញាតឱ្យអ្នកផ្សាយផ្តល់ឱ្យនូវកម្មវិធីដែលមានគុណភាពរូបភាព និងសម្លេងកាន់តែច្បាស់ល្អ ហើយផ្តល់នូវជម្រើសកម្មវិធីកាន់តែច្រើន និងធ្វើឱ្យមានសេវាកម្មផ្សេងៗដែលឥតប្រើខ្សែកាន់តែមានភាពជឿនលឿនសម្រាប់អតិថិជន ។

### តើខ្ញុំគួរធ្វើអ្វី ដើម្បីត្រៀមជាស្រេច ?

អ្នកមានជម្រើសបី :

1. ភ្ជាប់ទូរទស្សន៍អាណាឡូករបស់អ្នកនឹងប្រអប់សម្រាប់ប្តូរពីឌីជីថលទៅអាណាឡូក ។
ប្រអប់ប្តូរឌីជីថលទៅអាណាឡូក មាននៅតាមហាងលក់ហើយមានតម្លៃដែលទិញតែម្តងចប់ ត្រឹមតែ $40-$70 ។ ដើម្បីជួយអ្នកបង់ចំណាយសម្រាប់ការទិញប្រអប់នេះ រដ្ឋាភិបាលសហរដ្ឋអាមេរិកកំពុងផ្តល់នូវគូផុន(coupons)ដែលមានតម្លៃ $40 ចំនួនពីរ ក្នុងមួយគ្រួសារ ។ សម្រាប់ព័ត៌មានស្តីពីគូផុន សូមចូលទៅកាន់ www.DTV2009.gov ឬទូរស័ព្ទទៅលេខ 1-888-388-2009 (ជាសម្លេង) ឬ 1-877-530-2634 (TTY) ។ បន្ថែមលើនេះទៀត អ្នកមិនចាំបាច់ត្រូវការអង់តែនថ្មីទេ ប្រសិនបើអ្នកទទួលបាននូវភាពចាប់បានច្បាស់សម្រាប់ប៉ុស្តិ៍អាណាឡូក 2-51 ដោយអង់តែនដែលមានស្រាប់របស់អ្នកហើយ ។ ឬ

2. ទិញទូរទស្សន៍ឌីជីថល (ទូរទស្សន៍ដែលមានប្រដាប់រាវប៉ុស្តិ៍ឌីជីថលស្រាប់) ។
អ្នកមិនចាំបាច់ត្រូវការទូរទស្សន៍ប្រភេទដែលមានគុណភាពខ្ពស់ភ្លឺច្បាស់ [High Definition TV (HDTV)] ដើម្បីមើលការផ្សាយទូរទស្សន៍ជាឌីជីថលនោះទេ ។ អ្នកគ្រាន់តែត្រូវការទូរទស្សន៍ឌីជីថល (ឬទូរទស្សន៍អាណាឡូកដែលតភ្ជាប់ទៅនឹងប្រអប់សម្រាប់ប្តូរពីឌីជីថលទៅជាអាណាឡូក) ប៉ុណ្ណោះ ។ បន្ថែមលើនេះទៀត អ្នកមិនចាំបាច់ត្រូវការអង់តែនថ្មីទេ ប្រសិនបើអ្នកទទួលបាននូវការចាប់បានច្បាស់សម្រាប់ប៉ុស្តិ៍អាណាឡូក 2-51 ដោយអង់តែនរបស់អ្នកហើយ ។ ឬ

3. ទិញសេវាកម្មទូរទស្សន៍បង់ប្រាក់ ។
ប្រសិនបើទូរទស្សន៍របស់អ្នកទទួលស្ថានីយ៍ផ្សព្វផ្សាយក្នុងស្រុកតាមរយៈអ្នកផ្តល់សេវាបង់ប្រាក់ដូចជា ទូរទស្សន៍ខ្សែកាប ឬផ្កាយរណប វាត្រូវបានតម្លើងរួចជាស្រេចសម្រាប់ការផ្ទេរទៅកាន់ឌីធីវី ។ ក្រុមហ៊ុនខ្សែកាបមិនត្រូវបានតម្រូវឱ្យផ្ទេរ ឬប្តូរប៉ុស្តិ៍ណាមួយរបស់ពួកគេទៅកាន់ឌីជីថលនោះទេ ។ ទោះយ៉ាងណាប្រសិនបើអ្នកមានទូរទស្សន៍អាណាឡូក ដែលមិនទទួលបានស្ថានីយ៍ផ្សាយក្នុងស្រុកតាមរយៈអ្នកផ្តល់សេវាបង់ប្រាក់របស់អ្នក អ្នកនឹងត្រូវការប្រអប់សម្រាប់ប្តូរពីឌីជីថលទៅជាអាណាឡូក ដើម្បីមើលការផ្សាយតាមឌីជីថលលើទូរទស្សន៍នោះ ។

ដើម្បីទទួលបានព័ត៌មានបន្ថែម :

1-888-CALL-FCC (Voice) | DTV.gov | 1-888-TELL-FCC (TTY)

# THE DIGITAL TV TRANSITION

EPA United States Environmental Protection Agency

## What You Can Do with Your Analog TV

## តើខ្ញុំអាចបន្តប្រើទូរទស្សន៍អាណាឡូករបស់ខ្ញុំប្រកបដោយសារប្រយោជន៍ទៀតដោយរបៀបណា ?

ប្រសិនបើអ្នកមានទូរទស្សន៍អាណាឡូក ហើយនៅតែទទួលការផ្សាយតាមរលកធាតុអាកាស ដូច្នេះទីភ្នាក់ងារការពារបរិស្ថានសហរដ្ឋអាមេរិក (U.S. Environmental Protection Agency) សូមលើកទឹកចិត្តឱ្យអ្នកបន្តការប្រើទូរទស្សន៍របស់អ្នកតាមរយៈការតភ្ជាប់ទូរទស្សន៍នេះ ទៅនឹងប្រអប់បម្លែងប្រព័ន្ធពីឌីជីថល-ទៅ-អាណាឡូក ឬក៏ចុះឈ្មោះជាវប្រចាំជាមួយនឹងសេវាទូរទស្សន៍បង់ថ្លៃ ។



នៅពេលអ្នកទិញប្រអប់បម្លែងប្រព័ន្ធពីឌីជីថល-ទៅ-អាណាឡូក សូមមើលរកផលិតផលណា ដែលមានសរសេរអក្សរថា ENERGY STAR ។ ប្រអប់បម្លែងណាដែលមានលក្ខណៈសម្បត្តិ ENERGY STAR ប្រើថាមពលតិចជាងប្រអប់បម្លែងធម្មតា ។ ប្រសិនបើប្រអប់បម្លែងប្រព័ន្ធ ពីឌីជីថល-ទៅ-អាណាឡូកដែលបានដាក់លក់នៅក្នុង
ស.រ.អាទាំងអស់ បំពេញបានតាមលក្ខខណ្ឌ ENERGY STAR នោះយើងនឹងអាចសន្សំថាមពល 823 លានគីឡូវ៉ាត់ម៉ោងជារៀងរាល់ឆ្នាំ ។ បញ្ជីនៃគំរូផលិតផលដែលមានលក្ខណៈសម្បត្តិ ENERGY STAR អាចរកបានតាមរយៈគេហទំព័រ **www.energystar.gov/products** (សូមជ្រើសលើ Digital-to-Analog Converter Boxes) ។

## ប្រសិនបើខ្ញុំចង់ប្រើទូរទស្សន៍ចាស់របស់ខ្ញុំតទៅទៀត តើខ្ញុំគួរធ្វើដូចម្តេចជាមួយនឹងទូរទស្សន៍នោះ ?

**កែច្នៃវាជាថ្មី !** ប្រសិនបើអ្នកសម្រេចចិត្តទិញទូរទស្សន៍ឌីជីថលថ្មី ហើយមិនចង់រក្សាទុកទូរទស្សន៍អាណាឡូកចាស់របស់អ្នក ដូច្នេះសូមរកមើលឱកាសដើម្បីកែច្នៃជាថ្មី ។ ការកែច្នៃទូរទស្សន៍ជាថ្មី តម្រូវឱ្យមានវត្ថុធាតុដើមមានតម្លៃសម្រាប់តម្លើងឡើងវិញដូចជាបន្ទះសៀគ្វី ខ្សែលោហធាតុ កញ្ចក់សំណ និងប្លាស្ទិក ។ សូមទូរស័ព្ទទៅកាន់អ្នកប្រមូលសម្រាមដែលមានគ្រោះថ្នាក់នៅក្នុងផ្ទះប្រចាំតំបន់របស់អ្នក ឬក៏ទូរស័ព្ទទៅកាន់កម្មវិធីកែច្នៃជាថ្មីដើម្បីស្វែងយល់ថាតើពួកគេទាំងនោះ មានកម្មវិធីឆ្លើយតបទៅនឹងការកែច្នៃជាថ្មីនូវទូរទស្សន៍ និងគ្រឿងអេឡិចត្រូនិចផ្សេងៗទៀតនាពេលខាងមុខនេះដែរ ឬក៏អត់ ។ អ្នកក៏អាចត្រួតពិនិត្យមើលគេហទំព័រខាងក្រោមនេះ ដើម្បីស្វែងរកកម្មវិធីកែច្នៃជាថ្មីដែលនៅជិតអ្នកបំផុត :

ការកំណត់ធនធាន និងទីតាំងសម្រាប់ធ្វើការកែច្នៃគ្រឿងអេឡិចត្រូនិច មិនតម្រូវឱ្យមានការឯកភាពពី EPA ឡើយ ។

**Earth 911** **www.earth911.com/electronics** លេខកូដប្រៃសណីយ៍ Earth 911 ដោយពឹងផ្អែកលើមូលដ្ឋានម៉ាស៊ីនស្វែងរក អាចជួយឱ្យអ្នកស្វែងរកឃើញនូវជម្រើសនៃការកែច្នៃជាថ្មី និងការប្រើប្រាស់ឡើងវិញ សម្រាប់សហគមន៍របស់អ្នក ចំពោះផលិតផលជាច្រើនប្រភេទបាន ។

**National Recycling Coalition** **www.nrc-recycle.org/localresources.aspx** ទំព័រនេះផ្តល់ជូនអ្នកនូវការភ្ជាប់ទៅកាន់ធនធានកែច្នៃជាថ្មីរបស់រដ្ឋ ។ សហគមន៍ជាច្រើន ប្រារព្ធទិវានៃការប្រមូលសម្រាម និងទិវានៃការកែច្នៃជាថ្មី ដែលទិវាទាំងអស់នេះ សុទ្ធតែមានចុះជាសង្ខេបនៅលើគេហទំព័រ ។

**My Green Electronics** **www.mygreenelectronics.org** នៅលើគេហទំព័ររបស់សមាគមអ្នកប្រើប្រាស់ផលិតផលអេឡិច-ត្រូនិចមួយនេះ អ្នកអាចសិក្សាបន្ថែមអំពីការទិញផលិតផលអេឡិចត្រូនិច "ពណ៌បៃតង" និងអាចស្វែងរកឱកាសដើម្បីកែច្នៃជាថ្មីបានទៀតផង ។

សម្រាប់ផលិតផលអេឡូចត្រូនិចដែលនៅដំណើរការបាន ការបរិច្ចាគជាអំណោយ គឺជាជម្រើសដ៏ល្អបំផុត ព្រោះថាវាជួយសម្រួលឱ្យមានការប្រើប្រាស់ឡើងវិញ និងបន្តនូវអាយុកាលនៃផលិតផលនោះបានទៀតផង ។ ទោះជាដូច្នេះក៏ដោយ ដោយមានការផ្លាស់ប្តូរឆ្ពោះទៅរកការផ្សាយតាមប្រព័ន្ធឌីជីថល មានអង្គការសប្បុរសធម៌ជាច្រើន អាចមិនទទួលយកទូរទស្សន៍អាណាឡូកតទៅទៀតទេ ។ សូមសាកសួរអង្គការទាំងនោះ មុននឹងអ្នកបោះចោលទូរទស្សន៍អាណាឡូករបស់អ្នក ។